Australian Government

Department of Home Affairs

# Privacy notice
# ដំណឹងអំពីរឿងឯកជន

Form
**1442i KHM**
KHMER

Department of Home Affairs (ក្រសួងកិច្ចការក្នុងប្រទេស (ក្រសួង)) រួមមានកងកម្លាំងការពារព្រំដែនអូស្ត្រាលី។ *Privacy Act 1988* (*ច្បាប់រឿងឯកជន ឆ្នាំ១៩៨៨*(ច្បាប់រឿងឯកជន)) តម្រូវឲ្យក្រសួងជូនដំណឹងទៅបុគ្គលម្នាក់ៗអំពីរឿងជាក់លាក់ទាំងឡាយ ពេលណាក្រសួងប្រមូលយកព័ត៌មានផ្ទាល់ខ្លួនអំពីពួកគេ។ ហ្វ៊មនេះ គឺជាសេចក្ដីជូនដំណឹងរបស់លោកអ្នកអំពីរឿងទាំងនោះ។

## តើព័ត៌មានផ្ទាល់ខ្លួនជាអ្វី?

ច្បាប់រឿងឯកជនចែងថា ព័ត៌មានផ្ទាល់ខ្លួនគឺជាព័ត៌មាន ឬយោបល់អំពីបុគ្គលម្នាក់ដែលគេអាចសម្គាល់ដឹងដោយសមហេតុផល។

ក្រសួងក៏ប្រមូលយកព័ត៌មានផ្ទាល់ខ្លួនសំខាន់ជាក់លាក់ផងដែរ ដែលត្រូវបានកំណត់នៅក្រោមច្បាប់រឿងឯកជន ហើយមានរួមទាំងព័ត៌មានអំពីប្រភពដើមនៃពូជសាសន៍ ឬជនជាតិភាគតិច ចំណូលចិត្ត ឬការអនុវត្តន៍ខាងផ្លូវភេទ កំណត់ត្រាលើបទឧក្រិដ្ឋ ព័ត៌មានអំពីសុខភាព និងព័ត៌មានអំពីជីវមាត្រ សមាជិកភាពនៃអាជីវកម្ម ឬការប្រកបខាងមុខរបរ ជំនឿ ឬការចូលរួមសាសនា ជំនឿលើទស្សនវិជ្ជា ហើយនិងសមាជិកភាពនៃការចូលរួមផ្នែកនយោបាយ។

ផ្នែកសំខាន់ៗនៃច្បាប់នីតិបញ្ញត្តិចាត់ចែងដោយក្រសួងគឺ *Migration Act 1958* (Migration Act) (*ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៥៨*(ច្បាប់អន្តោប្រវេសន៍)), *Customs Act 1901* (Customs Act) *(ច្បាប់ពន្ធគយ ឆ្នាំ១៩០១* (ច្បាប់ពន្ធគយ)), *Immigration (Guardianship of Children) Act 1946* (IGOC Act) *(ច្បាប់អន្តោប្រវេសន៍(អាណាព្យាបាលកូន ឆ្នាំ១៩៤៦* (ច្បាប់ IGOC)), *Excise Act 1901* (Excise Act) (*ច្បាប់ពន្ធអាករ ឆ្នាំ១៩០១* (ច្បាប់ពន្ធអាករ)), *Australian Border Force Act 2015* (Border Force Act) *(ច្បាប់ពង្រឹងព្រំដែនអូស្ត្រាលី ឆ្នាំ២០១៥* (ច្បាប់ពង្រឹងព្រំដែនអូស្ត្រាលី)), *Maritime Powers Act 2013* (Maritime Powers Act) (*ច្បាប់នាវាចរណ៍សមុទ្រ ឆ្នាំ២០១៣* (ច្បាប់អំណាចគ្រប់គ្រងនាវាចរណ៍សមុទ្រ)), និង *Australian Citizenship Act 2007* (Citizenship Act) *(ច្បាប់សញ្ជាតិអូស្ត្រាលី ឆ្នាំ២០០៧* (ច្បាប់សញ្ជាតិ))។

## ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល

ច្បាប់អន្តោប្រវេសន៍ និងសញ្ជាតិ រួមមានខជាក់លាក់ទាំងឡាយអំពីការប្រមូលយក ការប្រើប្រាស់ និង/ឬការបញ្ចេញនូវព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក រួមមានព័ត៌មានសំខាន់ៗដូចជាជីវមាត្រ(ត្រូវបានគេហៅថា ‘ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល’)។

ច្បាប់កំណត់អត្ថន័យនៃព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល ដើម្បីរាប់បញ្ចូល:

- ស្នាមម្រាមដៃ ឬស្នាមបាតដៃ
- រូបភាពនៃមុខ និងស្មា
- ការថតសម្លេង ឬថតវីឌីអូ(សម្រាប់គោលបំណងនៃច្បាប់អន្តោប្រវេសន៍ប៉ុណ្ណោះដោយមានការលើកលែងដ៏មានកំរិតមួយចំនួន)
- ការវាស់កំពស់ និងទម្ងន់
- ការថតពិនិត្យប្រស្រីភ្នែក
- ហត្ថលេខារបស់បុគ្គលម្នាក់ ឬ
- ព័ត៌មានដែលអាចសំគាល់ដឹងដទៃណាមួយទៀត ដែលបានបង្គាប់ក្នុងបទបញ្ញត្តិ។

ព័ត៌មានផ្នែកជីវមាត្រ(ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល) អាចត្រូវគេប្រមូលយក និង/ឬផ្ទៀងផ្ទាត់មើលពីបុគ្គលផ្ទាល់:

- នៅព្រលានយន្តហោះក្នុងពេលធ្វើដំណើរ
- សម្រាប់អ្នកដាក់ពាក្យសុំទិដ្ឋាការពីក្នុងប្រទេស (រួមមានអ្នកដាក់ពាក្យសុំទិដ្ឋាការដែលមានកិច្ចការពារ)
- ដែលពុំមែនជាពលរដ្ឋនៅក្នុងសហគមន៍អូស្ត្រាលី
- ដែលជាអ្នកជាប់ឃុំឃាំងផ្នែកអន្តោប្រវេសន៍
- ដែលជាអ្នកដាក់ពាក្យសុំចូលសញ្ជាតិអូស្ត្រាលី។

## មុខការរបស់ក្រសួង និងព័ត៌មានលំអិតសម្រាប់ការទាក់ទងរបស់យើងខ្ញុំ

បេសកកម្មរបស់ក្រសួងគឺដើម្បីការពារព្រំដែនអូស្ត្រាលី និងការគ្រប់គ្រងចលនាមនុស្ស និងទំនិញឆ្លងកាត់ប្រទេសដោយការរួមចំណែកដល់ ហើយធានានូវ:

- អនាគតរបស់ប្រទេសអូស្ត្រាលី តាមរយៈអន្តោប្រវេសន៍ដែលត្រូវបានគ្រប់គ្រង
- កិច្ចការពារជនភៀសខ្លួន និងធ្វើវិភាគទានដល់គោលនយោបាយមនុស្សធម៌ទូទាំងអន្តរជាតិ
- សន្តិសុខរបស់ប្រទេសអូស្ត្រាលីតាមរយៈការគ្រប់គ្រងព្រំដែន និងការសម្របសម្រួលដល់អ្នកធ្វើដំណើរ
- ការប្រមូលយកស្ថិតិអំពីប្រាក់ចំណូល និងពាណិជ្ជកម្មតាមព្រំដែន
- ការសម្របសម្រួលនៃពាណិជ្ជកម្មស្របច្បាប់
- សន្តិសុខផ្នែកនាវាចរណ៍សមុទ្រ និងផលប្រយោជន៍ខាងពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី
- ការអនុលោមតាមច្បាប់អន្តោប្រវេសន៍ និងសុចរិតភាពរបស់ប្រទេសអូស្ត្រាលីក្នុងការធ្វើសេចក្ដីសំរេច
- ការចាត់ចែងច្បាប់សញ្ជាតិអូស្ត្រាលី។

ព័ត៌មានលំអិតពេញលេញសម្រាប់ការទាក់ទង អាចរកបានឃើញនៅតាមវ៉ិបសាយរបស់ក្រសួង **www.homeaffairs.gov.au**

ប្រសិនបើលោកអ្នកយល់ថាយើងខ្ញុំបានប្រមូលយក ឬកាន់កាប់ព័ត៌មានរបស់លោកអ្នកដោយខុសឆ្គង លោកអ្នកអាច:

- បំពេញពាក្យផ្ដល់យោបល់តបទៅវិញ តាមអ៊ីនធើណិតនៅត្រង់ **www.homeaffairs.gov.au/feedback**
- សរសេរទៅ:
  The Manager
  Global Feedback Unit
  GPO Box 241
  Melbourne VIC 3001
  Australia

## តើក្រសួងនឹងប្រមូលយកព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកអំពីនរណាខ្លះ

ជាទូទៅ ក្រសួង(ឬស្ថាប័នផ្ដល់សេវាក្រោមកិច្ចសន្យារបស់ខ្លួន) នឹងប្រមូលយកព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកផ្ទាល់ពីលោកអ្នក ភាគីទីបីដែលលោកអ្នកផ្ដល់សិទ្ធិឲ្យបំពេញកិច្ចការក្នុងនាមលោកអ្នក ឬប្រព័ន្ធដែលបានអនុញ្ញាតដូចបានកំណត់នៅក្រោមច្បាប់អន្តោប្រវេសន៍។ ប្រព័ន្ធដែលបានអនុញ្ញាតរួមមាន SmartGate និងប្រព័ន្ធត្រួតពិនិត្យព្រំដែនស្វ័យប្រវត្តិឯទៀត។ យើងខ្ញុំក៏អាចប្រមូលយកព័ត៌មានរបស់លោកអ្នកពីភាគីទីបីដែរ រួមមានភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីដទៃទៀត ភ្នាក់ងារអនុវត្តច្បាប់រដ្ឋាភិបាលបរទេស អ្នកធានាជួយផ្គត់ផ្គង់ គ្រូពេទ្យពិនិត្យជំងឺ អង្គការនានាដែលលោកអ្នកបានចាត់តាំង ស្ថាប័នអប់រំ និយោជក និងសមាជិកសាធារណៈដែលទាក់ទងក្រសួងដើម្បីផ្ដល់ព័ត៌មាន(ឧទាហរណ៍ ទូរស័ព្ទដើម្បីរាយការណ៍)។

© COMMONWEALTH OF AUSTRALIA, 2020

## ភ្នាក់ងារ ឬក្រុមហ៊ុនធ្វើការក្រោមកិច្ចសន្យាដែលចាត់ចែងសេវាកម្មអន្តោប្រវេសន៍

ព័ត៌មានផ្ទាល់ខ្លួនមួយចំនួនត្រូវបានប្រមូលយក និងប្រើប្រាស់ក្នុងនាមយើងខ្ញុំដោយភ្នាក់ងាររដ្ឋាភិបាលដទៃទៀត ដែលបានអនុញ្ញាតឲ្យចាត់ចែងបំពេញមុខការមួយចំនួនរបស់ក្រសួង។

ព័ត៌មានផ្ទាល់ខ្លួនក៏ត្រូវបានប្រមូលយក និងប្រើប្រាស់ផងដែរក្នុងនាមយើងខ្ញុំដោយក្រុមហ៊ុនធ្វើការក្រោមកិច្ចសន្យា។ ឧទាហរណ៍ខ្លះៗមានរួមទាំងការចាត់ចែងអ្នកដំណើរតាមរយៈប្រព័ន្ធធ្វើរបាយការណ៍ជឿនលឿនតាមបណ្តាញដោយក្រុមហ៊ុនអាកាសចរណ៍សម្រាប់ទាំងការហោះហើរធ្វើដំណើរចេញក្រៅ និងចូលក្នុងប្រទេស ប្រព័ន្ធខុមព្យូធើរ ការស្ទង់មតិតាមការស្រាវជ្រាវ/ការធ្វើសម្ភាសន៍ សេវាផ្គត់ផ្គង់សម្រាប់ជនដែលត្រូវបង្ខាំងទុកផ្នែកអន្តោប្រវេសន៍ និងសេវាផ្នែកពេទ្យ។

ក្រសួងតម្រូវថា ក្រុមហ៊ុនធ្វើការក្រោមកិច្ចសន្យារបស់ខ្លួនក៏ត្រូវអនុលោមតាមច្បាប់រឿងឯកជនដែរ ទោះថាក្រុមហ៊ុនធ្វើការក្រោមកិច្ចសន្យាទាំងនោះមានទីតាំងនៅក្នុងប្រទេសអូស្ត្រាលី ឬបរទេសក្តី។

## ការប្រមូលយកព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដែលបានតម្រូវ ឬអនុញ្ញាតដោយច្បាប់

ច្បាប់អន្តោប្រវេសន៍ ច្បាប់ IGOC ច្បាប់ពន្ធគយ ច្បាប់ពន្ធអាករ ច្បាប់អំណាចគ្រប់គ្រងនាវាចរណ៍សមុទ្រ ច្បាប់សញ្ជាតិ ហើយនិងច្បាប់រឿងឯកជន អនុញ្ញាត ហើយក្នុងករណីមួយចំនួន តម្រូវឲ្យក្រសួងប្រមូលយកព័ត៌មានផ្ទាល់ខ្លួនជាក់លាក់ដើម្បីចាត់ចែងច្បាប់ទាំងនេះ។

### ច្បាប់អន្តោប្រវេសន៍

ក្នុងទំនាក់ទំនងទៅនឹងពាក្យសុំទិដ្ឋាការ ក្រសួង:

- ត្រូវបានអនុញ្ញាតឲ្យប្រមូលយកព័ត៌មានណាមួយដែលពាក់ព័ន្ធនឹងពាក្យសុំ (មើលផ្នែក 56 នៃច្បាប់អន្តោប្រវេសន៍) ហើយ
- អាចតម្រូវឲ្យលោកអ្នកផ្តល់ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល (មើលផ្នែក 40 និង 46 នៃច្បាប់អន្តោប្រវេសន៍)។

អ្នកដាក់ពាក្យសុំទិដ្ឋាការ និងអ្នកកាន់ទិដ្ឋាការមួយចំនួនត្រូវប្រាប់ក្រសួងឲ្យបានដឹងអំពីការផ្លាស់ប្តូរក្នុងកាលៈទេសៈ ឬព័ត៌មានពុំត្រឹមត្រូវដែលបានផ្តល់នៅលើពាក្យសុំ (ផ្នែក 104 និង 105 នៃច្បាប់អន្តោប្រវេសន៍)។

ក្រសួងអាចតម្រូវឲ្យលោកអ្នកផ្តល់ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គលម្នាក់ ឬច្រើនជាងម្នាក់ សម្រាប់គោលបំណងនៃច្បាប់អន្តោប្រវេសន៍ និងបទបញ្ជាអន្តោប្រវេសន៍ ឆ្នាំ១៩៩៤។

ពេលចូលមកប្រទេសអូស្ត្រាលី ក្រសួងនឹងតម្រូវឲ្យលោកអ្នកផ្តល់ព័ត៌មានផ្ទាល់ខ្លួនជាក់លាក់(ឧទាហរណ៍ លិខិតឆ្លងដែនសម្រាប់ពលរដ្ឋ និងភស្តុតាងនៃអត្តសញ្ញាណ ហើយនិងទិដ្ឋាការសម្រាប់បុគ្គលដែលពុំមែនជាពលរដ្ឋ)។ ប្រសិនបើលោកអ្នកពុំមែនជាពលរដ្ឋ ហើយមិនបានផ្តល់ភស្តុតាងដែលតម្រូវទេ លោកអ្នកនឹងត្រូវគេបដិសេធមិនឲ្យចូលក្នុងប្រទេសអូស្ត្រាលីឡើយ(មើលផ្នែក 257A នៃច្បាប់អន្តោប្រវេសន៍)។

នៅពេលចាកចេញពីប្រទេសអូស្ត្រាលី ក្រសួងអាចតម្រូវឲ្យលោកអ្នកផ្តល់ព័ត៌មានជាក់លាក់ដែលអាចសំគាល់ដឹងអំពីបុគ្គល(មើលផ្នែក 257A នៃច្បាប់អន្តោប្រវេសន៍)។

ដើម្បីសំគាល់ដឹងអំពីបុគ្គលដែលពុំមែនជាពលរដ្ឋ ហើយខុសច្បាប់ ក្រសួងអាចតម្រូវ:

- ភស្តុតាងនៃអត្តសញ្ញាណ និងស្ថានភាពនៃទិដ្ឋាការ មានរួមទាំងព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល(មើលផ្នែក 188 នៃច្បាប់អន្តោប្រវេសន៍)
- បុគ្គលណាម្នាក់ឲ្យផ្តល់ឯកសារ ឬព័ត៌មានអំពីអត្តសញ្ញាណ ឬទីសំចតនៃអ្នកដែលត្រូវបានគេសង្ស័យថាជាមនុស្សដែលពុំមែនជាពលរដ្ឋ ហើយខុសច្បាប់ (មើលផ្នែក 18 នៃច្បាប់អន្តោប្រវេសន៍)។

ជនដែលនៅក្នុងទីឃុំឃាំងផ្នែកអន្តោប្រវេសន៍ ត្រូវផ្តល់ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល(មើលផ្នែក 258 និង 261AA(1) នៃច្បាប់អន្តោប្រវេសន៍ និងបទបញ្ជា 3.30 នៃបទបញ្ជាអន្តោប្រវេសន៍)។

ក្នុងបរិបទនៃអ្នកធានាជួយផ្គត់ផ្គង់ផ្នែកអាជីវកម្ម ក្រសួង ហើយនិង Fair Work Ombudsman (FWO) (មន្ត្រីផ្លូវការស៊ើបអង្កេតបណ្តឹងរបស់ពលរដ្ឋស្តីពីយុត្តិធម៌ការងារ (FWO)) អាចប្រមូលយកព័ត៌មានផ្ទាល់ខ្លួន ដោយអនុលោមតាមសិទ្ធអំណាចរបស់អ្នកត្រួតពិនិត្យក្នុងជំពូករង F នៃជំពូក 3A ភាគ 2 នៃច្បាប់អន្តោប្រវេសន៍។

សម្រាប់គោលបំណងនៃអំណាចឆែកឆេរមានក្នុងផ្នែក 252 នៃច្បាប់អន្តោប្រវេសន៍ ភ្នាក់ងារដែលមានការអនុញ្ញាតអាចបង្ខាំងទុកឯកសារណាមួយ ឬវត្ថុផ្សេងទៀតដែលគេរកឃើញនៅលើបុគ្គល ឬក្នុងទ្រព្យសម្បត្តិនៅក្រោមការគ្រប់គ្រងផ្ទាល់របស់បុគ្គល ឧទាហរណ៍ ដែលអាចជាភស្តុតាងសម្រាប់ការលុបចោលទិដ្ឋាការរបស់បុគ្គលនោះ

ភ្នាក់ងារណាម្នាក់ អាចរឹបអូសយកឯកសារក្លែងក្លាយណាមួយដែលក្លែងបន្លំ (មើលផ្នែក 487ZJ និងជំពូក 1 ភាគ 9 នៃច្បាប់អន្តោប្រវេសន៍ រួមមានរបៀបដែលគេត្រូវប្រឈមដោះស្រាយជាមួយនឹងឯកសារនោះ)។

### ច្បាប់ចូលសញ្ជាតិ

ក្រសួងអាចប្រមូលយកព័ត៌មានផ្ទាល់ខ្លួនមួយចំនួន ដើម្បីបំពេញតាមបំណងថាបុគ្គលម្នាក់បានបំពេញតាមតម្រូវការនៃភាពជាពលរដ្ឋ។

យើងខ្ញុំត្រូវបានអនុញ្ញាតដើម្បីស្នើសុំព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល ទាក់ទិននឹងពាក្យសុំចូលសញ្ជាតិ ហើយពាក្យសុំពុំអាចយល់ព្រមបានឡើយ ប្រសិនបើអ្នកធ្វើការសម្រេចចិត្ត ពុំបានពេញចិត្តនឹងអត្តសញ្ញាណរបស់លោកអ្នក(មើលជំពូក 5 ភាគ 2 និងផ្នែក 17(3), 19D(4), 24(3) និង 30(3) នៃច្បាប់សញ្ជាតិ)

ភ្នាក់ងារដែលបានទទួលអំណាច អាចរឹបអូសយកឯកសារក្លែងក្លាយណាមួយដែលក្លែងបន្លំ (មើលផ្នែក 45B និងជំពូក 1 ភាគ 3 នៃច្បាប់សញ្ជាតិ រួមមានរបៀបដែលគេត្រូវប្រឈមដោះស្រាយជាមួយនឹងឯកសារនោះ)។

### ច្បាប់ IGOC

នៅក្រោម *Immigration (Guardianship of Children) Act 1946* (IGOC Act) *(ច្បាប់អន្តោប្រវេសន៍(អាណាព្យាបាលកូន) ឆ្នាំ១៩៤៦* (ច្បាប់ IGOC)) និងបទបញ្ជារបស់ខ្លួន រដ្ឋមន្ត្រីក្រសួងអន្តោប្រវេសន៍ គឺជាអាណាព្យាបាលនៃក្មេងក្រោមអាយុពេញវ័យពុំមែនជាពលរដ្ឋជាក់លាក់ដែលគ្មាននរណាមកជាមួយ ដែលមកដល់ប្រទេសអូស្ត្រាលីពុំមានឳពុក ឬម្តាយ ឬញាតិសណ្តានអាយុ២១ ឬច្រើនជាងនេះ (ត្រូវគេហៅថា ក្មេងក្រោមអាយុពេញវ័យរបស់ IGOC)។

ដើម្បីជួយក្នុងការបំពេញតួនាទីខុសត្រូវជាអាណាព្យាបាល ច្បាប់ IGOC អនុញ្ញាតឲ្យរដ្ឋមន្ត្រីចាត់តាំងអំណាច និងមុខការអាណាព្យាបាលរបស់ខ្លួនទៅមន្ត្រីនៅក្នុងរដ្ឋាភិបាលសហព័ន្ធ ឬរដ្ឋ ឬដែនដី (ត្រូវគេហៅថា ‘អាណាព្យាបាលដែលបានចាត់តាំង’)។ បុគ្គល ឬអង្គការដែលមានឆន្ទៈ ឬសមរម្យ ក៏អាចត្រូវបានចាត់តាំងផងដែរជា ‘អ្នកថែរក្សា’ ក្មេងក្រោមអាយុពេញវ័យរបស់ IGOC។ ក្នុងលក្ខខណ្ឌទូទៅ អ្នកថែរក្សាមានសិទ្ធិ និងការទទួលខុសត្រូវដើម្បីធ្វើសេចក្តីសម្រេចអំពីការថែរក្សា និងការគ្រប់គ្រងប្រចាំថ្ងៃនៃកុមារដែលនៅក្រោមការថែរក្សារបស់ពួកគេ។

ដើម្បីធានាចំពោះការមើលថែពីមួយថ្ងៃទៅមួយថ្ងៃ និងសុខុមាលភាពសម្រាប់កុមារនៅក្រោមច្បាប់ IGOC ក្រសួងប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីក្មេងក្រោមអាយុពេញវ័យរបស់ IGOC និងអាណាព្យាបាលរបស់ពួកគេ។ ដើម្បីធានាចំពោះការមើលថែប្រចាំថ្ងៃ និងសេចក្តីត្រូវការរបស់ក្មេងក្រោមអាយុពេញវ័យរបស់ IGOC ត្រូវបានបំពេញកន្លែងណាដែលចាំបាច់ ហើយស្របទៅតាមច្បាប់រឿងឯកជន ក្រសួងអាចបញ្ចេញព័ត៌មានផ្ទាល់ខ្លួនទៅឲ្យ និងប្រមូលយកព័ត៌មានពី:

- អាជ្ញាធររដ្ឋ/ដែនដី រួមមានភ្នាក់ងារសុខុមាលភាពកុមារ
- អាណាព្យាបាលដែលបានចាត់តាំង
- អ្នកថែរក្សា
- មាតាបិតា អ្នកមើលថែ និង/ឬញាតិសណ្តាន និង/ឬ
- ភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីឯទៀត។


© COMMONWEALTH OF AUSTRALIA, 2020

## ច្បាប់ពន្ធគយ និងច្បាប់ពន្ធអាករ

ក្រសួងបានទទួលអំណាចដើម្បីប្រមូលយកព័ត៌មានផ្ទាល់ខ្លួន និងអាជីវកម្មមួយចំនួន ក្នុងការចាត់ចែងច្បាប់ពន្ធគយ និងច្បាប់ពន្ធអាករ ហើយនិងច្បាប់អូស្ត្រាលីដែល ពាក់ព័ន្ធឯទៀត (រួមមានច្បាប់អន្តោប្រវេសន៍ និងច្បាប់ពន្ធដារ)។ ជាពិសេស ក្រសួងប្រមូលយកព័ត៌មាននេះក្នុងកិច្ចការពារព្រំដែនអូស្ត្រាលី ហើយដើម្បីធានា លើការប្រមូលនៃប្រាក់ចំណូលតាមព្រំដែន។

នៅក្នុងករណីខ្លះ ហ្វ៊មរបស់យើងខ្ញុំដែលប្រមូលយកព័ត៌មានផ្ទាល់ខ្លួនអំពីលោកអ្នក ទាក់ទិននឹងរឿងទាំងឡាយកើតមានឡើងពីច្បាប់ពន្ធគយ និងច្បាប់ពន្ធដារ ក៏អាច មានដាក់នូវលិខិតប្រមូលពិសេសផងដែរ។ ហ្វ៊មទាំងនេះក៏ផ្តល់ជូនលោកអ្នកផងដែរ នូវព័ត៌មានជាក់លាក់ទាក់ទិននឹងការប្រមូលយក ការប្រើប្រាស់ និងការបញ្ចេញ ព័ត៌មានផ្ទាល់ខ្លួនដែលប្រមូលយកចេញពីឯកសារនោះ ហើយគួរតែបានអានរួមគ្នា ជាមួយនឹងដំណឹងអំពីរឿងឯកជន។

ឧទាហរណ៍ នៅក្រោមផ្នែក 64ACA និង 64ACB នៃច្បាប់ពន្ធគយ ក្រសួង បានតម្រូវឲ្យប្រមូលយកព័ត៌មានផ្ទាល់ខ្លួនជាក់លាក់ទាក់ទិននឹងក្រុមនាវា ឬយន្តហោះ ដែលមកដល់ប្រទេសអូស្ត្រាលី សម្រាប់គោលបំណងនៃការចាត់ចែងច្បាប់ពន្ធគយ ច្បាប់អន្តោប្រវេសន៍ និងច្បាប់ផ្សេងៗទៀត។

## ច្បាប់អំណាចគ្រប់គ្រងនាវាចរណ៍សមុទ្រ

ក្រសួងបានតម្រូវឲ្យប្រមូលយកព័ត៌មានផ្ទាល់ខ្លួន ក្នុងការអនុវត្តន៍អំណាចនាវាចរណ៍ សមុទ្រធ្វើឡើងដោយភ្នាក់ងារអនុវត្តច្បាប់តាមផ្លូវទឹក។ អំណាចទ្រទ្រង់ការអនុវត្តន៍ នៃនាវាចរណ៍សមុទ្ររបស់ប្រទេសអូស្ត្រាលីទាក់ទិននឹងច្បាប់ រួមមានក្នុងទំនាក់ទំនង ទៅនឹងការនេសាទត្រីនៃជនបរទេសដោយខុសច្បាប់ ពន្ធគយ ការប្រឆាំងទប់ទល់នឹង អំពើភេរវកម្មនាវាចរណ៍សមុទ្រ អន្តោប្រវេសន៍ ការដាក់ឲ្យនៅដាច់ពីគេដើម្បីការពារ រោគឆ្លង និងការជួញដូរគ្រឿងញៀនខុសច្បាប់ ព្រមទាំងកិច្ចព្រមព្រៀង និងការ រៀបចំអន្តរជាតិនៅតាមសមុទ្រផងដែរ។

## ច្បាប់រឿងឯកជន

ច្បាប់រឿងឯកជន អនុញ្ញាតឲ្យមានការប្រមូលយកនូវ:

- ព័ត៌មានរឿងឯកជនសំខាន់ កន្លែងណាដែលបានអនុញ្ញាតក្រោមផ្លូវច្បាប់ ឬសម្រាប់ការអនុវត្តន៍ទាំងឡាយទាក់ទិននឹងការប្រតិបត្តិផ្លូវច្បាប់ ឬដោយមាន ការយល់ព្រមពីលោកអ្នក
- ព័ត៌មានផ្ទាល់ខ្លួនដទៃទៀតដែលជាការចាំបាច់សមហេតុផល ឬទាក់ទិនផ្ទាល់ ទៅនឹងការបំពេញមុខងារ ឬសកម្មភាពមួយ ឬច្រើនរបស់ក្រសួង។

## ច្បាប់នានានៅក្រោមក្រសួងដែលជាភ្នាក់ងារអនុវត្តច្បាប់

ក្រសួងគឺជាភ្នាក់ងារអនុវត្តច្បាប់ សម្រាប់គោលបំណងជាក់លាក់មួយចំនួននៅក្រោម ច្បាប់ដូចតទៅនេះ: *Crimes Act 1914* (ច្បាប់ព្រហ្មទណ្ឌ ឆ្នាំ១៩១៤), *Criminal Code Act 1995 (ច្បាប់ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៩៥), Australian Nuclear Science and Technology Organisation Act 1987* (ANSTO Act) *(ច្បាប់អង្គការវិទ្យាសាស្ត្រ និង បច្ចេកវិទ្យានុយក្លេអ៊ែរអូស្ត្រាលី ឆ្នាំ១៩៨៧* (ANSTO Act)), *Independent National Security Legislation Monitor Act 2010* (ហើយនិង*ច្បាប់ត្រួតពិនិត្យ នីតិកម្មសន្តិសុខជាតិឯករាជ្យ ឆ្នាំ២០១០)* ហើយអាចប្រ មូលយកព័ត៌មានផ្ទាល់ខ្លួនក្នុងគោលបំណងដើម្បីអនុវត្តមុខការ និងសកម្មភាពរបស់ខ្លួន នៅក្រោមច្បាប់ទាំង នោះ។

## គោលបំណងដែលយើងខ្ញុំប្រមូលយកព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក

គោលបំណងចម្បងរបស់យើងខ្ញុំចំពោះការប្រមូលយកព័ត៌មានផ្ទាល់ខ្លួន គឺដើម្បីអនុវត្ត ការបំពេញមុខងារ ឬសកម្មភាពរបស់ក្រសួងទាក់ទិននឹងផ្លូវលំផ្នែកអន្តោប្រវេសន៍ និង/ឬភាពជាសញ្ជាតិរបស់លោកអ្នក និងចលនានៃទំនិញឆ្លងកាត់ព្រំដែន។ យើងខ្ញុំ គ្រប់គ្រងកម្មវិធីនានាដូចតទៅនេះ:

- ទិដ្ឋាការ និងការធ្វើអន្តោប្រវេសន៍
- ពន្ធគយ និងពន្ធដារ រួមមានការចាត់ចែងនៃច្បាប់អូស្ត្រាលីជាក់លាក់ឯទៀត មានរួមទាំងច្បាប់ពន្ធដារ សុខភាព ការដាក់ឲ្យនៅដាច់ពីគេដើម្បីការពាររោគឆ្លង ពាណិជ្ជកម្ម ឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិបញ្ញវន្ត និងកិច្ចការពារសហគមន៍
- ជំនួយផ្នែកមនុស្សធម៌ និងជនភៀសខ្លួន
- ការគ្រប់គ្រងព្រំដែន
- ការអនុលោមតាមទិដ្ឋាការ និងដំណោះស្រាយស្ថានភាពអន្តោប្រវេសន៍
- ការជាប់ឃុំឃាំងផ្នែកអន្តោប្រវេសន៍ ការនាំចេញ ឬការបញ្ជូនទៅមជ្ឈមណ្ឌល ចាត់ចែងក្នុងតំបន់ (រួមមានស្ថាប័នផ្តល់សេវា និងអាជ្ញាធរបរទេសក្នុងការគាំទ្រ នៃការចាត់ចែងនៅក្រៅប្រទេស ដូចជាការពង្រឹងច្បាប់ ការផ្គត់ផ្គង់សេវាសុខុ មាលភាព និងការតាំងទីលំនៅ)
- ភាពជាសញ្ជាតិ។

ព័ត៌មានដែលលោកអ្នកផ្តល់ឲ្យក្នុងទិដ្ឋាការ ពាក្យសុំសម្រាប់ការធានា ពាណិជ្ជកម្ម ការនាំចូល និងការនាំចេញ ការដាក់ឲ្យនៅដាច់ពីគេដើម្បីការពាររោគឆ្លង ឬពាក្យ សុំចូលសញ្ជាតិ នឹងត្រូវបានគេយកប្រើសម្រាប់គោលបំណងចម្បងនោះ។

ក្រោមច្បាប់រឿងឯកជន ព័ត៌មានក៏អាចត្រូវគេយកប្រើសម្រាប់គោលបំណងបន្ទាប់បន្សំ ដែរ។ ជាទូទៅ នេះគឺជាកន្លែងដែលលោកអ្នកនឹងរំពឹងទុកដោយសមហេតុផលថា ក្រសួងនឹងប្រើ ឬបញ្ចេញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ហើយគោលបំណងបន្ទាប់ បន្សំគឺថាទាក់ទិនផ្ទាល់ទៅនឹងគោលបំណងចម្បង (ចំពោះព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន) ឬក៏ទាក់ទិនផ្ទាល់ទៅនឹងគោលបំណងចម្បង (សម្រាប់ព័ត៌មានផ្ទាល់ខ្លួនដទៃទៀត)។ ឧទាហរណ៍ ព័ត៌មានដែលលោកអ្នកផ្តល់ឲ្យក្នុងពាក្យសុំទិដ្ឋាការ អាចគេយកប្រើទាក់ ទិននឹងពាក្យសុំបន្ទាប់ក្រោយទៀតរបស់លោកអ្នក (មានរួមទាំងនៅក្រោម *Freedom of Information Act 1982* (*ច្បាប់សេរីភាពដើម្បីទទួលយកព័ត៌មាន*))។ ជាបន្ថែម ទៀត យើងខ្ញុំអាចប្រើប្រាស់ព័ត៌មានទាក់ទងបែបអេឡិចត្រូនិចដែលលោកអ្នកបាន ផ្តល់ឲ្យ ដើម្បីទាក់ទងជាមួយលោកអ្នកអំពីបញ្ហាអន្តោប្រវេសន៍ទាំងឡាយ។

## ផលវិបាកទាំងឡាយ ប្រសិនបើក្រសួងពុំប្រមូលមានព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក

ប្រសិនបើគេពុំប្រមូលយកបានព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកទេ ក្រសួងប្រហែលជា ពុំអាចចាត់ចែងពាក្យសុំទិដ្ឋាការ ឬពាក្យសុំចូលសញ្ជាតិរបស់លោកអ្នក ឬ(កន្លែង ណាដែលពាក់ព័ន្ធ) ផ្តល់សេវាផ្គត់ផ្គង់ផ្នែកពាណិជ្ជកម្ម ការនាំចូល និងការនាំចេញ ការដាក់ឲ្យនៅដាច់ពីគេដើម្បីការពាររោគឆ្លងជូនលោកអ្នកឡើយ។

ការខកខានពុំបានប្រមូលយកព័ត៌មានរបស់លោកអ្នក អាចរារាំងសមត្ថភាពរបស់ក្រសួង ដើម្បីបំពេញតាមកាតព្វកិច្ចកំណត់ដោយច្បាប់របស់ខ្លួន(ជាពិសេសទាក់ទិននឹងការ គោរពតាមច្បាប់) ភារកិច្ចនៃករណីកិច្ចមើលថែរបស់ខ្លួន ឬការប្តូរផ្តាច់ផ្នែកអន្តរជាតិ របស់ប្រទេសអូស្ត្រាលី។

## ការបញ្ចេញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកតាមធម្មតាទៅឲ្យភាគីទីបី

### ការបញ្ចេញព័ត៌មានទៅអ្នកតំណាងដែលបានចាត់តាំង

កន្លែងណាដែលលោកអ្នកបានចាត់តាំងមនុស្សម្នាក់ ដូចជាសមាជិកគ្រួសារ ភ្នាក់ងារ អន្តោប្រវេសន៍ អ្នកវិជ្ជាជីវៈខាងពន្ធគយ ភ្នាក់ងារធ្វើដំណើរ ឬភ្នាក់ងារអាកាសចរណ៍ មន្ត្រីផ្លូវការស៊ើបអង្កេតបណ្តឹងរបស់ពលរដ្ឋ សមាជិកសភា ឬអ្នកច្បាប់ដើម្បីតំណាងឲ្យ លោកអ្នក ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកអាចត្រូវគេបញ្ចេញទៅឲ្យភាគីទីបីទាំងនោះ លើកលែងតែលោកអ្នកបានស្នើសុំកុំឲ្យយើងខ្ញុំធ្វើដូច្នោះ។

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក អាចត្រូវគេបញ្ចេញទៅឲ្យបុគ្គលដែលលោកអ្នកធានា ជួយផ្គត់ផ្គង់ ឬអ្នកធានាជួយផ្គត់ផ្គង់របស់លោកអ្នក។

### ការបញ្ចេញព័ត៌មានតាមធម្មតាទៅឲ្យភ្នាក់ងាររដ្ឋាភិបាលដទៃទៀត

ក្នុងកាលៈទេសៈជាក់លាក់ ក្រសួងបានទទួលសិទ្ធិ និងអនុញ្ញាតនៅក្រោមច្បាប់ពង្រឹង ព្រំដែន ឬបញ្ញត្តិឯទៀតដើម្បីបញ្ចេញព័ត៌មានផ្ទាល់ខ្លួនទៅឲ្យភ្នាក់ងាររដ្ឋាភិបាលដទៃ ទៀតដូចជាសម្រាប់គោលបំណងនៃការចាត់ចែងមុខការ និងសកម្មភាពរបស់ខ្លួន ឬដើម្បីឲ្យអាច ឬជួយភ្នាក់ងារឯទៀតបំពេញមុខការរបស់ពួកគេ។ ឧទាហរណ៍ មានរួមទាំងការបញ្ចេញព័ត៌មានដើម្បីបញ្ជាក់អត្តសញ្ញាណរបស់លោកអ្នក ផ្ទៀងផ្ទាត់ ភាពពិតប្រាកដនៃឯកសារដែលលោកអ្នកបានផ្តល់ឲ្យ ទទួលធ្វើការប្រៀបធៀបទិន្នន័យ ឬដើម្បីគ្រប់គ្រងកាតព្វកិច្ចនៃការអនុលោមតាមច្បាប់។

ភ្នាក់ងាររដ្ឋាភិបាលដែលយើងខ្ញុំផ្ដោះប្ដូរព័ត៌មានជាមួយ មានរួមទាំង ក៏ប៉ុន្តែពុំមែនកំណត់តែត្រឹមនេះឡើយ:

- ក្រសួងកិច្ចបំរើប្រជាជន (DHS) ដើម្បីចាត់ចែង *Social Security Act 1991 (ច្បាប់សន្តិសុខសង្គម ឆ្នាំ១៩៩១), Child Support (Assessment) Act 1989 (ច្បាប់ការវាយតម្លៃផ្គត់ផ្គង់កុមារ (ការវាយតម្លៃ) ឆ្នាំ១៩៨៩))* និង *Child Support (Registration and Collection) Act 1988 (ច្បាប់ផ្គត់ផ្គង់កុមារ (ការចុះឈ្មោះ និងការប្រមូលយក) ឆ្នាំ១៩៨៨))*
- ក្រសួងកិច្ចបម្រើសង្គមកិច្ច
- ក្រសួងកសិកម្ម ដើម្បីគ្រប់គ្រងប្រព័ន្ធជីវៈសន្តិសុខរបស់ប្រទេសអូស្ត្រាលី និងការចាត់ចែងនៃ *Quarantine Act 1908 (ច្បាប់ការដាក់ឲ្យនៅដាច់ពីគេ ដើម្បីការពាររោគឆ្លង ឆ្នាំ១៩០៨), Export Control Act 1982 (ច្បាប់គ្រប់គ្រងការនាំចេញ ឆ្នាំ១៩៨២)* និង *Imported Food Control Act 1992 (ច្បាប់គ្រប់គ្រងចំណីអាហារនាំចូល ឆ្នាំ១៩៩២)*
- ការចាត់ចែងទំនិញខាងការព្យាបាល
- ក្រសួងឧស្សាហកម្ម ថ្មៃប្រឌិត និងវិទ្យាសាស្ត្រ
- Australian Sports Anti-Doping Authority (អាជ្ញាធរប្រឆាំងនឹងគ្រឿងញៀនប្រើប្រាស់ក្នុងកីឡាអូស្ត្រាលី) ដើម្បីចាត់ចែង National Anti-Doping Scheme (គ្រោងការណ៍ជាតិប្រឆាំងនឹងគ្រឿងញៀន)
- ក្រសួងអប់រំ ដើម្បីចាត់ចែង *Education Services for Overseas Students Act 2000 (ច្បាប់សេវាអប់រំសិស្សបរទេស ឆ្នាំ២០០០)*
- ក្រសួងការងារ អាជីវកម្មខ្នាតតូច និងជាលក្ខណៈគ្រួសារ ដើម្បីប្រៀបធៀបព័ត៌មានទិន្នន័យអំពីសេវារកការងារធ្វើ
- ក្រសួងកិច្ចការអតីតយុទ្ធជន ដើម្បីចាត់ចែង *Veterans' Entitlements Act 1986 (ច្បាប់ភាពមានសិទ្ធទទួលបានរបស់អតីតយុទ្ធជន ឆ្នាំ១៩៨៦)*
- ការិយាល័យពន្ធដារអូស្ត្រាលី (ATO) ដើម្បីចាត់ចែង *Income Tax Assessment Act 1997 (ច្បាប់ពិនិត្យវាយតម្លៃពន្ធដារលើប្រាក់ចំណូល ឆ្នាំ១៩៩៧)* និងច្បាប់ពន្ធដារឯទៀត
- មន្ត្រីផ្លូវការស៊ើបអង្កេតបណ្ដឹងរបស់ពលរដ្ឋស្ដីពីយុត្តិធម៌ការងារ (FWO) ដើម្បីចាត់ចែង *Fair Work Act 2009 (ច្បាប់យុត្តិធម៌ការងារ ឆ្នាំ២០០៩)*
- ក្រសួងការបរទេស និងជំនួញ (DFAT) ដើម្បីចាត់ចែង *Australian Passport Act 2005 (ច្បាប់លិខិតឆ្លងដែនអូស្ត្រាលី ឆ្នាំ២០០៥)* និងដើម្បីទទួលបានព័ត៌មានក្នុងប្រទេស សម្រាប់ការចាត់ចែងទិដ្ឋាការដែលមានកិច្ចការពារ ហើយដែលទាក់ទិននឹងទិដ្ឋាការបរទេសណាមួយ ដែលលោកអ្នកអាចមានសិទ្ធិកាន់កាប់ក្នុងឋានៈជាទ្វេសញ្ជាតិ។
- គណៈកម្មការរៀបចំការបោះឆ្នោតអូស្ត្រាលី ដើម្បីចាត់ចែង *Commonwealth Electoral Act 1918 (ច្បាប់បោះឆ្នោតសហព័ន្ធ ឆ្នាំ១៩១៨)*។

## ស្ថាប័នពិនិត្យឡើងវិញ ការជម្រះបញ្ជី និងការស៊ើបអង្កេត

ប្រសិនបើលោកអ្នកដាក់ពាក្យសុំការពិនិត្យឡើងវិញអំពីគុណសម្បត្តិ ឬការសម្រេចសេចក្ដីរបស់តុលាការ ក្រសួងនឹងផ្ដល់ព័ត៌មានផ្ទាល់ខ្លួនពាក់ព័ន្ធទៅឲ្យតុលាការ ឬសាលាក្ដីដែលចាត់ចែងការពិនិត្យឡើងវិញនោះ។

យើងខ្ញុំចែករំលែកព័ត៌មានជាមួយស្ថាប័នស៊ើបអង្កេតទាំងឡាយ មានដូចជា:

- មន្ត្រីផ្លូវការស៊ើបអង្កេតបណ្ដឹងរបស់ពលរដ្ឋពាក់ព័ន្ធរឿងរ៉ាវសហព័ន្ធ
- ការិយាល័យស្នងការព័ត៌មានអូស្ត្រាលី
- ការិយាល័យជម្រះបញ្ជីជាតិអូស្ត្រាលី
- គណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី
- មន្ត្រីផ្លូវការស៊ើបអង្កេតបណ្ដឹងរបស់ពលរដ្ឋស្ដីពីយុត្តិធម៌ការងារ។

## សេវាកម្មគ្រោះមានអាសន្ន និងការប្រតិបត្តិផ្លូវច្បាប់

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក អាចផ្ដល់ទៅឲ្យភ្នាក់ងារអនុវត្តច្បាប់អូស្ត្រាលី ឬសេវាកម្មគ្រោះមានអាសន្នក្នុងព្រឹត្តិការណ៍នៃគ្រោះមានអាសន្ន ការរងរបួសធ្ងន់ធ្ងរ ឬការស្លាប់។ ក្រសួងក៏អាចបញ្ចេញព័ត៌មានផ្ទាល់ខ្លួនទៅឲ្យភ្នាក់ងារអនុវត្តច្បាប់អូស្ត្រាលី (សហព័ន្ធ រដ្ឋ និងដែនដី) និងនៅឯបរទេសផងដែរ កន្លែងណាចាំបាច់ សម្រាប់ការអនុវត្តន៍សកម្មភាពដែលពាក់ព័ន្ធ រួមមានកិច្ចការពារ ការតាមដាន ការស៊ើបអង្កេត និងការកាត់ទោស ឬការដាក់ទោសបទឧក្រិដ្ឋទាំងឡាយ។

## កម្មវិធីទំនុកបំរុង

ព័ត៌មានដែលប្រមូលយកក្នុងការចាត់ចែងទិដ្ឋាការ អាចបញ្ចេញទៅឲ្យ:

- ក្រសួងកិច្ចបម្រើសង្គមកិច្ច ដើម្បីផ្ដល់ការទំនុកបំរុងផ្នែកតាំងទីលំនៅ
- ក្រសួងឧស្សាហកម្ម ថ្មៃប្រឌិត និងវិទ្យាសាស្ត្រ ដើម្បីជួយសម្រួល និងត្រួតពិនិត្យការហ្វឹកហ្វឺនភាសាអង់គ្លេស។

## ការបញ្ចេញទៅឲ្យអាជ្ញាធរចេញអាជ្ញាបណ្ណ

ប្រសិនបើលោកអ្នកដាក់ពាក្យសុំអាជ្ញាបណ្ណក្នុងប្រទេសអូស្ត្រាលី ក្រសួងអាចបញ្ចេញទៅឲ្យអាជ្ញាធរពាក់ព័ន្ធនូវព័ត៌មានអំពីស្ថានភាពនៃការធ្វើអន្តោប្រវេសន៍ និងភាពមានសិទ្ធធ្វើការងាររបស់លោកអ្នក ហើយក្នុងករណីមួយចំនួន ថាតើលោកអ្នកបានទទួលសិទ្ធជាសញ្ជាតិអូស្ត្រាលីឬអត់។ ព័ត៌មាននេះនឹងត្រូវគេប្រើប្រាស់ដើម្បីវាយតម្លៃភាពសមស្របរបស់លោកអ្នកដើម្បីកាន់កាប់អាជ្ញាបណ្ណ។ មានការបញ្ចេញជាកំលាក់ផងដែរដែលអាចធ្វើឡើង ប្រសិនបើលោកអ្នកដាក់ពាក្យសុំសម្រាប់អាជ្ញាបណ្ណជាកំលាក់នៅក្រោមច្បាប់ពន្ធគយ។

## ការបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលបានអនុញ្ញាត

'ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល' ត្រូវបានកំណត់អត្ថន័យនៅទំព័រ 1។

ក្រសួងមានសិទ្ធអនុញ្ញាតនៅក្រោមផ្នែក 4A នៃច្បាប់អន្តោប្រវេសន៍ និង s43 នៃច្បាប់ចូលសញ្ជាតិ ដើម្បីបញ្ចេញព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គលក្នុងកាលៈទេសៈផ្សេងៗគ្នាមួយចំនួន។ ឧទាហរណ៍ទាំងឡាយមានរួមទាំង:

- ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពជាសញ្ជាតិ ឬទិដ្ឋាការ
- សម្រាប់ការប្រតិបត្តិនៃច្បាប់ឧក្រិដ្ឋ
- ការផ្ដោះប្ដូរព័ត៌មានដែលសំគាល់ដឹង ក្រោមការរៀបចំជាមួយភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលី
- រៀបចំឲ្យមានព័ត៌មានពាក់ព័ន្ធសម្រាប់តុលាការ សាលាក្ដី ឬស្ថាប័នស៊ើបអង្កេត
- កន្លែងណាដែលតម្រូវដោយច្បាប់អូស្ត្រាលី។

ក្រសួងក៏មានសិទ្ធអំណាចក្រោមច្បាប់សញ្ជាតិផងដែរ ដើម្បីបញ្ចេញព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល សម្រាប់គោលបំណងនៃនីតិបញ្ញត្តិនៃភាពជាសញ្ជាតិ ឬអន្តោប្រវេសន៍។

ផ្នែក 4A នៃច្បាប់អន្តោប្រវេសន៍ក៏អនុញ្ញាតឲ្យក្រសួងបញ្ចេញព័ត៌មានផ្ទាល់ខ្លួនផងដែរ (មានរួមទាំងព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល) ក្នុងកាលៈទេសៈទាំងឡាយដូចតទៅនេះ:

- ប្រៀបធៀបទិន្នន័យដើម្បី:
  - សំគាល់ដឹង ឬបញ្ជាក់ភាពពិតប្រាកដនៃអត្តសញ្ញាណរបស់បុគ្គលម្នាក់
  - ជួយសម្រួលដល់ការចាត់ចែងឲ្យមនុស្សចូលមក ឬចាកចេញពីប្រទេសអូស្ត្រាលី
  - សំគាល់ដឹងមនុស្សដែលពុំមែនជាពលរដ្ឋ ដែលមានប្រវត្តិបទឧក្រិដ្ឋមានអត្តចរិកគួរឲ្យបារម្ភ ឬដែលបារម្ភដល់សន្តិសុខជាតិ
  - ប្រយុទ្ធនឹងការក្លែងបន្លំឯកសារ និងអត្តសញ្ញាណក្នុងបញ្ហារឿងអន្តោប្រវេសន៍
  - ជួយដល់ការចាត់ចែងទិដ្ឋាកិច្ចការពារ
- ដើម្បីសំគាល់ដឹង ឬរកឲ្យឃើញមនុស្ស (មើលផងដែរនៅផ្នែក **33FA** និង **33FC** នៃច្បាប់អន្តោប្រវេសន៍)
- ទៅស្ថាប័នស៊ើបអង្កេតដែលបានដាក់បញ្ញត្តិ ដូចជាការិយាល័យជម្រះបញ្ជីជាតិអូស្ត្រាលី និងគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលីជាដើម។
- ធ្វើការរៀបចំសម្រួលជាមួយរដ្ឋាភិបាលបរទេសនានា សម្រាប់ការយកចេញពីប្រទេសអូស្ត្រាលី ឬសម្រាប់គោលបំណងធ្វើបត្យាប័នមនុស្សទៅកាន់ ឬត្រឡប់មកពីប្រទេសអូស្ត្រាលីវិញ។


© COMMONWEALTH OF AUSTRALIA, 2020

- ដើម្បីរៀបចំឲ្យមានព័ត៌មានសម្រាប់រដ្ឋាភិបាលបរទេសនានាដែលបានបញ្ជាក់ច្បាស់លាស់ ស្ថាប័នការប្រតិបត្តិផ្លូវច្បាប់ ឬស្ថាប័នត្រួតពិនិត្យព្រំដែននៃរដ្ឋាភិបាលបរទេស ឬអង្គការអន្តរជាតិដែលបានបញ្ជាក់ច្បាស់លាស់សម្រាប់គោលបំណងគ្រប់គ្រងបញ្ហាអន្តោប្រវេសន៍(មើលផ្នែក **5A(3)** នៃច្បាប់អន្តោប្រវេសន៍)។
- ការទទួលបានជំនួយ ឬផ្តល់ជំនួយក្នុងបញ្ហាបទឧក្រិដ្ឋអន្តរជាតិ។

ដើម្បីទទួលបានព័ត៌មានច្រើនទៀតអំពី ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល សូមមើលហ្វ៊ម 1243i។

ក្នុងទំនាក់ទំនងទៅនឹងទិដ្ឋាការអ្នកធ្វើការ ក្រសួងក៏ត្រូវបានអនុញ្ញាតផងដែរដើម្បីបញ្ចេញព័ត៌មានផ្ទាល់ខ្លួនជាក់លាក់អំពីអ្នកធានាជួយផ្គត់ផ្គង់ ឬអ្នកកាន់ទិដ្ឋាការទៅនឹងអ្នកកាន់ទិដ្ឋាការ ឬអ្នកធានាជួយផ្គត់ផ្គង់ស្របគ្នា(មើលផ្នែក 140ZH នៃច្បាប់អន្តោប្រវេសន៍ និងបទបញ្ញត្តិ 2.103, 2.104 និង 2.105)។

ក្រសួងក៏ត្រូវបានអនុញ្ញាតផងដែរ ដើម្បីបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលជាព័ត៌មានផ្នែកអន្តោប្រវេសន៍ និងកិច្ចការពារព្រំដែន (មើលផ្នែក 4(1) នៃច្បាប់ពង្រឹងព្រំដែន) ក្នុងកាលៈទេសៈដ៏កំណត់ដូចបានគូសបញ្ជាក់ក្នុងផ្នែក 6 នៃច្បាប់ពង្រឹងព្រំដែន។ ក្នុងកាលៈទេសៈជាក់លាក់ ច្បាប់ពង្រឹងព្រំដែនអនុញ្ញាតចំពោះការបញ្ចេញទៅឲ្យអង្គការនានាដូចតទៅនេះ:

- ភ្នាក់ងារ ឬអាជ្ញាធរសហព័ន្ធ រដ្ឋ និងដែនដី
- ប៉ូលីសសហព័ន្ធអូស្ត្រាលី (AFP) ឬកងប៉ូលីស ឬសេវារដ្ឋ ឬសហព័ន្ធ
- អ្នកធ្វើសពវិភាគ
- អ្នកកាន់កាប់មុខដំណែងដោយច្បាប់នៅតាមសហព័ន្ធ រដ្ឋ និងដែនដី (ឧទាហរណ៍ មន្ត្រីផ្លូវការស៊ើបអង្កេតបណ្តឹងរបស់ពលរដ្ឋ)
- អង្គការ ឬមនុស្សដែលត្រូវបានតែងតាំងដោយកងត្រួតពិនិត្យព្រំដែនអូស្ត្រាលី (Secrecy and Disclosure) (ការសំងាត់ និងការបញ្ចេញ) វិន័យ 2015 ដូចជាសង្គមកាកបាតក្រហមអូស្ត្រាលី
- អង្គការនៅឯបរទេស ឬអង្គការអន្តរជាតិសាធារណៈ។

ទោះជាយ៉ាងណាក្តី បន្ថែមទៅនឹងតម្រូវការជាក់លាក់ឯទៀតនៅក្នុងផ្នែក 6 នៃច្បាប់ពង្រឹងព្រំដែន ការបញ្ចេញព័ត៌មានផ្ទាល់ខ្លួននៅក្រោមច្បាប់ពង្រឹងព្រំដែននឹងត្រូវបានអនុញ្ញាតចំពោះតែអង្គការមួយ ក្នុងចំណោមអង្គការខាងលើនេះប៉ុណ្ណោះ ប្រសិនបើការបញ្ចេញនោះត្រូវបានធ្វើឡើងសម្រាប់ 'គោលបំណងដែលត្រូវបានអនុញ្ញាត' មួយ ឬច្រើនជាងដូចមានចុះនៅក្នុងច្បាប់ពង្រឹងព្រំដែន។ ឧទាហរណ៍ រាប់បញ្ចូលទាំងកន្លែងណាដែលការបញ្ចេញ គឺសម្រាប់គោលបំណងណាមួយដូចតទៅនេះ:

- ការចាត់ចែង ឬការអនុវត្តន៍នៃច្បាប់ព្រហ្មទណ្ឌ ឬច្បាប់ណាមួយទាក់ទងនឹងពាណិជ្ជកម្ម
- ការជួយដល់ការស៊ើបអង្កេត ការតាមដាន ឬការអង្កេតលើការធ្វើសពវិភាគ
- កិច្ចការពារសុខភាពសាធារណៈ ឬជីវិត ឬសុវត្ថិភាពរបស់បុគ្គលម្នាក់ ឬច្រើនជាងម្នាក់
- ការប្រមូលយក ឬផ្ទៀងផ្ទាត់ទិន្នន័យនៅក្រោម *Census and Statistics Act 1905 (ច្បាប់ជំរឿនប្រជាជន និងស្ថិតិ ឆ្នាំ១៩០៥)* ឬ *Australian Bureau of Statistics Act 1975 (ច្បាប់ការិយាល័យស្ថិតិអូស្ត្រាលី ឆ្នាំ១៩៧៥)*
- កិច្ចការពារប្រាក់ចំណូលសាធារណៈ
- ការសំគាល់ឲ្យដឹងអំពីបុគ្គល ឬការផ្ទៀងផ្ទាត់អំពីភាពជាពលរដ្ឋ ឬទិដ្ឋាការរបស់គេ
- ការចាត់ចែងសេវានានាទៅឲ្យបុគ្គលដែលពុំមែនជាពលរដ្ឋអូស្ត្រាលី
- ការចាត់ចែងនៃគ្រោងការណ៍ជាតិប្រឆាំងនឹងគ្រឿងញៀន
- គោលបំណងទាក់ទិននឹងផ្នែកអន្តោប្រវេសន៍ ការដាក់ឲ្យនៅដាច់ពីគេដើម្បីការពាររោគឆ្លង ឬការគ្រប់គ្រងព្រំដែនរវាងប្រទេសអូស្ត្រាលី និងប្រទេសនៅឯបរទេស
- បញ្ហាគ្របដណ្តប់ដោយច្បាប់មួយចំនួន រួមមាន Customs Act (ច្បាប់ពន្ធគយ), Migration Act (ច្បាប់អន្តោប្រវេសន៍), Maritime Powers Act (ច្បាប់អំណាចគ្រប់គ្រងនាវាចរណ៍សមុទ្រ), Citizenship Act (ច្បាប់សញ្ជាតិ), IGOC Act។ល។
- គោលបំណងទាក់ទិននឹងកិច្ចការពារ និងសន្តិសុខជាតិ។

ក្រសួងក៏ត្រូវបានអនុញ្ញាតផងដែរ ដើម្បីបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលជាព័ត៌មានត្រូវបានគេការពារ ប្រសិនបើបុគ្គលយល់ព្រមឲ្យបញ្ចេញ ការបញ្ចេញគឺជាការចាំបាច់ដើម្បីបង្ការ ឬកាត់បន្ថយការបៀតបៀនយាយីធ្ងន់ធ្ងរណាមួយទៅដល់ជីវិត ឬសុខភាពរបស់បុគ្គលណាម្នាក់ ឬព័ត៌មានត្រូវបានធ្វើឡើងជាសាធារណៈដោយស្របច្បាប់រួចស្រេចហើយ។

ផ្នែក 51 នៃច្បាប់ពង្រឹងព្រំដែនចែងថា ការបញ្ចេញដែលអនុលោមតាមខជាក់លាក់មានក្នុងផ្នែក 6 នៃច្បាប់នោះ នឹងត្រូវបានចាត់ទុកថាជាការបញ្ចេញដែលត្រូវបានអនុញ្ញាតដោយច្បាប់នោះ សម្រាប់គោលបំណងនៃច្បាប់រឿងឯកជន។

ជាបន្ថែម ការបញ្ចេញនូវព័ត៌មានផ្នែកអន្តោប្រវេសន៍ និងកិច្ចការពារព្រំដែនត្រូវបានអនុញ្ញាតនៅក្រោមច្បាប់ពង្រឹងព្រំដែន ប្រសិនបើត្រូវបានធ្វើឡើងក្នុងដំណើរនៃសេវា ឬការងាររបស់ជនដែលបានទុកចិត្តលើសម្រាប់ក្រសួង។ ក្រសួងនឹងធានាថាការបញ្ចេញដូចនេះណាមួយត្រូវអនុលោមតាមច្បាប់រឿងឯកជន។

ក្រសួងក៏ត្រូវបានអនុញ្ញាតផងដែរដើម្បីបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលជាព័ត៌មានត្រូវបានគេការពារក្នុងកាលៈទេសៈដ៏កំណត់ ដែលត្រូវបានពិចារណាក្នុងច្បាប់ពន្ធគយដែលទាក់ទិនមានដូចជាច្បាប់ពន្ធគយ និងបទបញ្ញានានា។

## ការបញ្ចេញកំណត់ត្រាចលនា

កំណត់ត្រាអំពីការមកដល់ និងការចេញដំណើរនៃអ្នកធ្វើដំណើរទៅ និងមកពីប្រទេសអូស្ត្រាលី ត្រូវបានរក្សាទុកក្នុងសំណុំទិន្នន័យកំណត់ត្រាចលនា។ កំណត់ត្រាទាំងនេះអាចបញ្ចេញសម្រាប់គោលបំណងនេះ:

- ច្បាប់អន្តោប្រវេសន៍
- *Family Law Act 1975 (ច្បាប់គ្រួសារ ឆ្នាំ១៩៧៥)*
- ច្បាប់ពន្ធគយ ឬពន្ធអាករ
- ច្បាប់ដាក់ឲ្យនៅដាច់ពីគេដើម្បីការពាររោគឆ្លង ឬច្បាប់សុខភាព
- ការអនុវត្តន៍ច្បាប់
- *Education Services for Overseas Students Act 2000 (ច្បាប់សេវាអប់រំសិស្សបរទេស ឆ្នាំ២០០០)*
- នីតិបញ្ញត្តិសហព័ន្ធ រដ្ឋ ឬដែនដីដែលបានដាក់បញ្ញត្តិ ដូចជាការចាត់ចែងកម្មវិធីម្ចាស់ផ្ទះទីមួយ ឬកម្មវិធីកុមារ និង/ឬសុខុមាលភាព។

## ការបញ្ចេញព័ត៌មានសម្រាប់ការប្រតិបត្តិផ្លូវច្បាប់ និងគោលបំណងទាក់ទិនទាំងឡាយ

ការបញ្ចេញព័ត៌មានតាមធម្មតាធ្វើឡើងដោយក្រសួង សម្រាប់ការប្រតិបត្តិផ្លូវច្បាប់ និងគោលបំណងទាក់ទិនទាំងឡាយ (មានរួមទាំងសម្រាប់សកម្មភាពប្រតិបត្តិផ្លូវច្បាប់នៅក្រោមច្បាប់អន្តោប្រវេសន៍ និងច្បាប់សញ្ជាតិ ហើយនិងសកម្មភាពប្រតិបត្តិផ្លូវច្បាប់របស់ភ្នាក់ងារប្រតិបត្តិផ្លូវច្បាប់ឯទៀត) រួមមាន:

- ភ្នាក់ងារអនុវត្តច្បាប់នៅបរទេស និងអូស្ត្រាលី ដើម្បីវាយតម្លៃ និងបង្កាប់បញ្ហាចំពោះតម្រូវការនៃអត្តចរិក
- ភ្នាក់ងារអនុវត្តច្បាប់នៅបរទេស និងអូស្ត្រាលី និងភ្នាក់ងារ ឬគណៈកម្មការស៊ើបការណ៍ សេវាកម្មប៉ូលីសរួមជាតិ ប៉ូលីសអន្តរជាតិ មជ្ឈមណ្ឌលកំណត់គោលដៅលើព្រំដែនជាតិ ជវិមទរាច្ក ៀសទព្យ្ក គណៈកម្មការត្រួតពិនិត្យគណៈកម្មការសភាស៊ើបអង្កេត តុលាការអន្តរជាតិ និងអាជ្ញាធរអន្តោប្រវេសន៍បរទេសដើម្បីសំគាល់ដឹង ឬស៊ើបអង្កេតអំពីការក្លែងបន្លំផ្នែកអន្តោប្រវេសន៍ បញ្ហាសន្តិសុខជាតិ ឬការជាប់ទាក់ទងក្នុងបទឧក្រិដ្ឋសង្គ្រាមដែលត្រូវបានសង្ស័យ ឬបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ
- គណៈកម្មការអនុវត្តច្បាប់សុចរិតភាពអូស្ត្រាលី ដើម្បីចាត់ចែង *Law Enforcement Integrity Commissioner Act 2006 (ច្បាប់ស្នងការអនុវត្តច្បាប់សុចរិតភាព ឆ្នាំ២០០៦)*
- ATO, DHS និងភ្នាក់ងារសហព័ន្ធ រដ្ឋ និងដែនដីឯទៀតដើម្បីស្វែងរកជនដែលកំពុងធ្វើការដោយបំពានលក្ខខណ្ឌទិដ្ឋាការទាក់ទិននឹងការងាររបស់គេ។
- AFP និងកងកម្លាំងប៉ូលីសអូស្ត្រាលី ដើម្បីស្វែងរកមនុស្សដែលពុំមែនជាពលរដ្ឋហើយរស់នៅខុសច្បាប់
- នាយកអយ្យការសាធារណៈ កាត់ទោសបទល្មើសផ្នែកអន្តោប្រវេសន៍ ឬភាពជាសញ្ជាតិ

- រដ្ឋាភិបាលបរទេសសម្រាប់ការយកចេញមនុស្សដែលពុំមែនជាពលរដ្ឋ ហើយខុសច្បាប់
- FWO វិទ្យាស្ថានអប់រំដែលបានចុះបញ្ជីស្របច្បាប់ និយោជក អ្នកដែលគេធានាជួយផ្គត់ផ្គង់ អ្នកធានាជួយផ្គត់ផ្គង់ អ្នកផ្គត់ផ្គង់កម្លាំងពលកម្ម ដើម្បីត្រួតពិនិត្យការគោរពតាមលក្ខខណ្ឌនៃទិដ្ឋាការ និងកាតព្វកិច្ចនៃការធានាជួយផ្គត់ផ្គង់ ហើយជូនដំណឹងអំពីករណីនៃការដាក់ទណ្ឌកម្ម។
- ភ្នាក់ងារអនុវត្តច្បាប់រួមមាន AFP ក្នុងទំនាក់ទំនងទៅនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំទិដ្ឋាការ និងអ្នកដាក់ស្នើនៅក្រោមកម្មវិធីជនភៀសខ្លួន និងមនុស្សធម៌ ដើម្បីសម្គាល់ដឹងអំពីបញ្ហាអនុវត្តច្បាប់ និងបញ្ហាសន្តិសុខជាតិណាមួយ។

## ការបញ្ចេញព័ត៌មានធ្វើឡើងដោយក្រសួងក្នុងឋានៈជាភ្នាក់ងារអនុវត្តច្បាប់

ក្រសួងគឺជាភ្នាក់ងារអនុវត្តច្បាប់ សម្រាប់គោលបំណងជាក់លាក់មួយចំនួននៅក្រោមច្បាប់ដូចតទៅនេះ: *Crimes Act 1914* (ច្បាប់ព្រហ្មទណ្ឌ ឆ្នាំ១៩១៤), *Criminal Code Act 1995 (ច្បាប់ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៩៥), Australian Nuclear Science and Technology Organisation Act 1987* (ANSTO Act) *(ច្បាប់អង្គការវិទ្យាសាស្ត្រ និង បច្ចេកវិទ្យានុយក្លេអ៊ែរអូស្ត្រាលី ឆ្នាំ១៩៨៧* (ANSTO Act)), *Independent National Security Legislation Monitor Act 2010* (ហើយនិង*ច្បាប់ត្រួតពិនិត្យ នីតិកម្មសន្តិសុខជាតិឯករាជ្យ ឆ្នាំ២០១០)* ហើយអាចប្រមូលយកព័ត៌មានផ្ទាល់ខ្លួន ក្នុងគោលបំណងដើម្បីអនុវត្តមុខការ និងសកម្មភាពរបស់ខ្លួននៅក្រោមច្បាប់ទាំងនោះ។

## ការបញ្ចេញព័ត៌មានឯទៀតទាក់ទិននឹងការគ្រប់គ្រងកម្មវិធី

### ការធានាជួយផ្គត់ផ្គង់

ព័ត៌មានទាក់ទិននឹងមនុស្សដែលផ្តល់ការធានាជួយផ្គត់ផ្គង់ នឹងត្រូវបញ្ចេញទៅឲ្យ Centrelink ដើម្បីជួយសម្រួលដល់ការបញ្ចេញប្រាក់ធានាដែលបានបង់ ឬអត្តសញ្ញាណកម្ម និងការទារមកវិញនូវប្រាក់បំណុលដែលបានកើតឡើង។

### ការងារ ការផ្គត់ផ្គង់កម្លាំងពលកម្ម និងជំនាញផ្នែកអាជីវកម្ម

ក្រសួងអាចបញ្ចេញព័ត៌មានអំពីស្ថានភាពនៃការធ្វើអន្តោប្រវេសន៍របស់លោកអ្នក ភាពមានសិទ្ធធ្វើការ និងប្រភេទ និងរយៈពេលនៃទិដ្ឋាការរបស់លោកអ្នកទៅឲ្យនិយោជក អ្នកផ្គត់ផ្គង់កម្លាំងពលកម្ម និងភាគីទីបីដែលប្រើប្រាស់សេវារបស់លោកអ្នក តាមរយៈការរៀបចំឲ្យមានការផ្គត់ផ្គង់ពលកម្ម។ ឧទាហរណ៍ នៅពេលលោកអ្នកដាក់ពាក្យសុំធ្វើការ ក្រសួងអាចបញ្ចេញព័ត៌មានទៅឲ្យនិយោជក ឬអ្នកផ្គត់ផ្គង់មនុស្សធ្វើការ អំពីភាពមានសិទ្ធធ្វើការរបស់លោកអ្នក។

ក្រសួងក៏អាចបញ្ចេញព័ត៌មានផងដែរទៅឲ្យក្រសួង និងភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចនៃរដ្ឋ និងដែនដីដែលជួយជនអន្តោប្រវេសន៍មានជំនាញផ្នែកអាជីវកម្ម ឲ្យមានលទ្ធភាពទទួលបានសេវាផ្តល់ព័ត៌មានផ្នែកអាជីវកម្មរបស់រដ្ឋាភិបាល។

### ការហ្វឹកហ្វឺន និងការអប់រំ

ព័ត៌មានផ្ទាល់ខ្លួនអាចបញ្ចេញទៅឲ្យ:

- ឧឈាទ ក្រសួងឧស្សាហកម្ម និងក្រសួងអប់រំ ដើម្បីជួយអស់អ្នកស្វែងរកទទួលការហ្វឹកហ្វឺន ឬសិក្សាក្នុងប្រទេសអូស្ត្រាលី
- ក្រសួងការងារ ដើម្បីកំណត់អំពីការប៉ះទង្គិចណាមួយនៃផ្នែកនៅកន្លែងធ្វើការដែលបានស្នើឡើងតាមទីផ្សារកម្លាំងពលកម្មអូស្ត្រាលី
- ក្រសួងអប់រំ និងអាជ្ញាធរដែលបានទទួលសិទ្ធអំណាច ជាអ្នកវាយតម្លៃគុណសម្បត្តិមកពីបរទេសសម្រាប់ថ្នាក់ទិដ្ឋាការមួយចំនួន
- វិទ្យាស្ថានអប់រំ ដែលផ្តល់ការបង្ហាត់បង្រៀនភាសាអង់គ្លេសក្រោមកម្មវិធីបង្រៀនភាសាអង់គ្លេសសម្រាប់ជនប្រវេសន៍ពេញវ័យ
- អង្គការរដ្ឋាភិបាលសម្រាប់គោលបំណងនៃការចេញបញ្ញត្តិស្ថាប័នអប់រំ។

### សុខភាព

ព័ត៌មានលំអិតអំពីសុខភាពរបស់លោកអ្នក និងសមាជិកគ្រួសាររបស់លោកអ្នកដូចដែលបានវាយតម្លៃសម្រាប់ពាក្យសុំទិដ្ឋាការរបស់លោកអ្នក អាចត្រូវគេបញ្ចេញទៅឲ្យភ្នាក់ងារសុខភាពរដ្ឋាភិបាល និងស្ថាប័នពេទ្យដើម្បីជួយក្នុងការកំណត់ថាតើតម្រូវការផ្នែកសុខភាពត្រូវបានបំពេញតាមសម្រាប់ការផ្តល់ឲ្យទិដ្ឋាការឬអត់ សម្រាប់ការពិចារណាថាតើតម្រូវការផ្នែកសុខភាពគួរតែបានបដិសេធ ឬសម្រាប់ការគ្រប់គ្រងលើគ្រោះថ្នាក់សុខភាពសាធារណៈ។

### ការចូលមកក្នុងឋានៈជនភៀសខ្លួន និងមនុស្សធម៌ និងកិច្ចការពារក្នុងប្រទេស

ក្រសួងអាចផ្ទេរព័ត៌មានផ្ទាល់ខ្លួននៃអ្នកចូលមកក្នុងឋានៈជនភៀសខ្លួន និងមនុស្សធម៌ និងអ្នកដាក់ស្នើរបស់គេ(បើអាចអនុវត្តបាន) ទៅឲ្យស្ថាប័នផ្តល់សេវាជាប់កិច្ចសន្យា សម្រាប់ការតាំងទីលំនៅបែបមនុស្សធម៌។

ក្រសួងអាចផ្ទេរព័ត៌មានផ្ទាល់ខ្លួនទាក់ទងនឹងអ្នកស្វែងរកសិទ្ធជ្រកកោន និងអ្នកស្នើសុំទិដ្ឋាការដែលមានកិច្ចការពារ ឬទិដ្ឋាការមនុស្សធម៌ ទៅឲ្យឧត្តមស្នងការនៃអង្គការសហប្រជាជាតិ សម្រាប់ជនភៀសខ្លួន (UNHCR) សម្រាប់គោលបំណងនៃការផ្ទៀងផ្ទាត់អត្តសញ្ញាណ និងការទាមទារផ្នែកមនុស្សធម៌ និងកិច្ចការពារ។

ក្រសួងក៏អាចផ្តល់ព័ត៌មានផ្ទាល់ខ្លួនផងដែរទៅឲ្យអង្គការអន្តរជាតិ សម្រាប់ការធ្វើអន្តោប្រវេសន៍ដើម្បីជួយដល់ការផ្គត់ផ្គង់សេវាកម្មរបស់គេ។

### ការឃុំឃាំង

ក្រសួងអាចផ្តល់ព័ត៌មានផ្ទាល់ខ្លួន ទាក់ទងនឹងជនដែលត្រូវបង្ខាំងទុកផ្នែកអន្តោប្រវេសន៍ទៅឲ្យ:

- ភ្នាក់ងារសុខុមាលភាពរដ្ឋ និងដែនដី ទាក់ទិននឹងការរៀបចំឲ្យមានការឃុំឃាំងតាមរបៀបផ្សេង ការថែទាំសម្រាប់ក្មេងក្រោមអាយុពេញវ័យដែលគ្មាននរណាមកជាមួយ ឬភាពជាអ្នកគ្រប់គ្រងសម្រាប់ជនជនជាប់ឃុំឃាំងដែលមានពិការភាពផ្នែកសុខភាព រាងកាយ និងផ្លូវចិត្ត
- សេវាអប់រំនៅតាមមន្ទីរឃុំឃាំងរដ្ឋ និងដែនដី ដើម្បីជួយសម្រួលដល់ការបញ្ជូន និងបញ្ជាក់អំពីស្ថានភាពអន្តោប្រវេសន៍
- ស្ថាប័នផ្តល់សេវាចាត់ចែងនៅក្រៅប្រទេស ក្នុងការផ្គត់ផ្គង់ការបញ្ជូន
- សាលារៀន គ្រូពេទ្យពិនិត្យជំងឺ ស្ថាប័នផ្តល់សេវាសុខភាព និងសុខុមាលភាព ឬអ្នកផ្តល់ឱវាទផ្នែកអន្តោប្រវេសន៍ដែលផ្តល់សេវាជូនលោកអ្នក ឬវាយតម្លៃជម្រើសទាំងឡាយដើម្បីជួយលោកអ្នក ឬគ្រួសាររបស់លោកអ្នកក្នុងការចេញដំណើរ។

### សុខុមាលភាព និងកិច្ចការពារកុមារ

ព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ និង/ឬឪពុកម្តាយ/អាណាព្យាបាល/អ្នកមើលថែកុមារ អាចត្រូវគេបញ្ចេញទៅឲ្យភ្នាក់ងារសុខុមាលភាព និងកិច្ចការពារកុមារ ទៅឲ្យភ្នាក់ងារសុខុមាលភាពកុមាររដ្ឋ/ដែនដី ប៉ូលីសរដ្ឋ/ដែនដី ឬភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីពាក់ព័ន្ធឯទៀត ដើម្បី:

- ចាត់ចែង និងត្រួតពិនិត្យការរៀបចំឲ្យមានការមើលថែ និងសុខុមាលភាពក្នុងមន្ទីរឃុំឃាំងផ្នែកអន្តោប្រវេសន៍ និង/ឬក្នុងសហគមន៍
- ស៊ើបអង្កេតអំពីការរំលោភបំពាន ឬការធ្វេសប្រហែសដែលអាចមាន
- ជួយសម្រួលដល់ការរៀបចំការធ្វើដំណើរ និងការកត់ត្រាជាឯកសារ។

ព័ត៌មានទាក់ទងនឹងកុមារដែលចូលមកប្រទេសអូស្ត្រាលី សម្រាប់ការទទួលយកក្មេងមកចិញ្ចឹម អាចត្រូវគេបញ្ចេញទៅឲ្យអង្គការសុខុមាលភាពរដ្ឋ និងដែនដី Central Adoption Authorities (អាជ្ញាធរកណ្តាលត្រួតពិនិត្យ ការទទួលយកក្មេងមកចិញ្ចឹមរបស់ប្រទេសអូស្ត្រាលី) និង Intercountry Adoption Australia (អង្គការអន្តរប្រទេសទទួលយកក្មេងមកចិញ្ចឹមនៃអូស្ត្រាលី)។


© COMMONWEALTH OF AUSTRALIA, 2020

### ព័ត៌មានសម្រាប់ស្ថានទូត ឧត្តមស្នងការ និងស្ថានកុងស៊ុលដើម្បីទទួលបានឯកសារធ្វើដំណើរ

ប្រសិនបើលោកអ្នកត្រូវបានគេយល់ព្រមផ្តល់ឲ្យទិដ្ឋាការ ដោយសំអាងលើហេតុផលនៃការចេញដំណើរ ឬពុំមានគោលការណ៍ស្របច្បាប់ដើម្បីនៅក្នុងប្រទេសអូស្ត្រាលី លោកអ្នកត្រូវបានគេរំពឹងទុកឲ្យធ្វើដំណើរចាកចេញ។ ប្រសិនបើលោកអ្នកពុំកាន់ ឬទទួលបានឯកសារធ្វើដំណើរដែលមានសុពលភាព ក្នុងរង្វង់ពេលដែលបានតម្រូវដោយសមហេតុផលទេ នេះគឺជាការអនុវត្តទូទៅរបស់ក្រសួងដើម្បីស្នើសុំឯកសារមួយក្នុងនាមលោកអ្នក។ ការនេះអនុញ្ញាតឲ្យមានការរៀបសម្រួលសម្រាប់ការចេញដំណើររបស់លោកអ្នក។

ក្រសួងនឹងផ្តល់ព័ត៌មានយ៉ាងតិចបំផុតប៉ុណ្ណោះ ដែលតម្រូវដោយស្ថានទូតសមរម្យ ឧត្តមស្នងការ ឬស្ថានកុងស៊ុល ដើម្បីជួយសម្រួលដល់ការផ្តល់ឯកសារធ្វើដំណើរ។ ព័ត៌មាននេះអាចមានរួមទាំងឈ្មោះរបស់លោកអ្នក ព័ត៌មានលំអិតនៃលិខិតឆ្លងដែនបច្ចុប្បន្នរបស់លោកអ្នក ឬឯកសារអត្តសញ្ញាណដទៃទៀត និងព័ត៌មានលំអិតសម្រាប់ការទាក់ទង។

### ភាពជាសញ្ជាតិ

ក្រសួងអាចផ្តល់ព័ត៌មានផ្ទាល់ខ្លួន ក្រៅពីព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គលទៅឲ្យ:

- សាលាក្រុងក្នុងតំបន់ និងអង្គការដទៃទៀតសម្រាប់គោលបំណងនៃការចាត់ចែង និងការរៀបចំការប្រារព្ធពិធីចូលសញ្ជាតិ
- ការិយាល័យមន្ត្រីលេខាធិការផ្លូវការទៅអគ្គទេសាភិបាល និងក្រសួងនាយករដ្ឋមន្ត្រី និងខុទ្ទកាល័យដើម្បីពិចារណាលើការស្នើសុំឥស្សរយសអូស្ត្រាលី
- សមាជិកសភា និងទីប្រឹក្សាសាលាក្រុង សម្រាប់គោលបំណងទទួលស្វាគមន៍ពលរដ្ឋថ្មីៗមកក្នុងសហគមន៍អូស្ត្រាលី។

### ការស្រាវជ្រាវអំពីការធ្វើអន្តោប្រវេសន៍

ព័ត៌មានផ្ទាល់ខ្លួនអាចគេយកប្រើសម្រាប់ការស្ទង់មតិអតិថិជនបច្ចុប្បន្ន និងពីមុនៗ។ ព័ត៌មានផ្ទាល់ខ្លួនអាចគេបញ្ចេញទៅឲ្យភ្នាក់ងារដទៃទៀត និងភាគីទីបីដែលជាប់កិច្ចសន្យាសម្រាប់គោលបំណងនៃការស្រាវជ្រាវ ការស៊ើបអង្កេត និងការធ្វើវិភាគសម្រាប់គោលនយោបាយ និង/ឬកម្មវិធីអភិវឌ្ឍន៍។ កិច្ចសន្យាករិតលើការប្រើប្រាស់របស់ខ្លួនសម្រាប់គោលបំណងនៃការស្រាវជ្រាវដែលបានថ្លែងបញ្ជាក់ ហើយតម្រូវឲ្យមានការបំផ្លាញវាចោលនៅពេលបំពេញរួច។ ទិន្នន័យដែលបានប្រមូលយក និងប្រើប្រាស់ក្នុងការស្រាវជ្រាវត្រូវបានធ្វើកុំឲ្យគេសម្គាល់ដឹង មុនពេលចេញផ្សាយ។

ព័ត៌មានផ្ទាល់ខ្លួនអាចត្រូវគេបញ្ចេញទៅឲ្យការិយាល័យស្ថិតិអូស្ត្រាលី ដើម្បីជួយសម្រួលដល់ការស្រាវជ្រាវផ្អែកប្រជាសាស្ត្រលើអ្នកមកដល់ថ្មីៗ និងការធ្វើវិភាគលើកម្មវិធីផ្អែកអន្តោប្រវេសន៍ផ្សេងៗគ្នា និងលទ្ធផលនៃការតាំងទីលំនៅ។

ព័ត៌មានទាក់ទងនឹងអ្នកទើបមកដល់ថ្មីៗ អាចផ្តល់ទៅឲ្យភ្នាក់ងាររដ្ឋ និងដែនដី ឬអង្គការផ្តល់សេវាជនអន្តោប្រវេសន៍ ដើម្បីជួយដល់ការធ្វើគម្រោងតាំងទីលំនៅ ឬផ្តល់សេវាតាំងទីលំនៅ។

## ព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ

ព័ត៌មានផ្ទាល់ខ្លួនអាចត្រូវគេបញ្ចេញទៅឲ្យភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលី រួមមានភ្នាក់ងាររដ្ឋ និងដែនដីដែលមានតួនាទីសម្របសម្រួលក្នុងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗដូចជា: ការប្រកួតកីឡា និងការលេងល្បែងសំខាន់ៗ ការប្រជុំអ្នកដឹកនាំរដ្ឋពីអន្តរជាតិ ផ្នែកសង្គម ពិធីបុណ្យ ឬការជួបជុំគ្នាផ្នែកវប្បធម៌ ឬសាសនាពិភពលោក។

ក្រសួងក៏អាចប្រើ និងបញ្ចេញព័ត៌មានផ្ទាល់ខ្លួនផងដែរទៅឲ្យអង្គការអូស្ត្រាលី និងអន្តរជាតិ ហើយនិងប្រទេសដទៃទៀតដើម្បីជួយសម្រួលដល់កិច្ចសម្រុះសម្រួលទាំងឡាយរបស់លោកអ្នក។

## ព័ត៌មានអំពីគោលនយោបាយរឿងឯកជនរបស់ក្រសួង

គោលនយោបាយរឿងឯកជនរបស់ក្រសួង មានផ្តល់នៅតាមវិបសាយរបស់ក្រសួង **https://www.homeaffairs.gov.au/access-and-accountability/our-commitments/privacy**

គោលនយោបាយមានចុះព័ត៌មានអំពី:

- របៀបដែលលោកអ្នកអាចប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដែលកាន់កាប់ដោយក្រសួង ហើយស្វែងរកការកែតម្រូវអំពីព័ត៌មាននោះ
- របៀបដែលលោកអ្នកអាចតវ៉ាអំពីការបំពានរឿងឯកជន និងនីតិវិធីគ្រប់គ្រងការតវ៉ារបស់ក្រសួង។

## ការបញ្ចេញព័ត៌មានរបស់លោកអ្នក ទៅឲ្យអ្នកទទួលនៅបរទេស

ក្រសួងប្រើប្រាស់ក្រុមហ៊ុនធ្វើការក្រោមកិច្ចសន្យាខាងក្រៅផ្នែកព័ត៌មានបច្ចេកវិទ្យាដើម្បីផ្ទេរ និងរក្សាទុកទិន្នន័យ រួមមានស្ថាប័នផ្តល់សេវាដែលមានទីតាំងនៅបរទេស។

នៅក្នុងកាលៈទេសៈខ្លះ យើងខ្ញុំបញ្ចេញព័ត៌មានផ្ទាល់ខ្លួនទៅឲ្យអ្នកទទួលនៅបរទេស។ ជាញឹកញាប់ អ្នកទទួលគឺជាប្រទេសនៃទីកន្លែងរស់នៅធម្មតារបស់លោកអ្នក ឬប្រទេសដែលលោកអ្នកបានចេញដំណើរ (លើកលែងតែលោកអ្នកបានធ្វើពាក្យបណ្តឹងទាមទារសម្រាប់កិច្ចការពារប្រឆាំងនឹងបណ្តាប្រទេសទាំងនោះ ហើយកំពុងរង់ចាំការវាយតម្លៃនៃការទាមទារទាំងនោះដែលនឹងត្រូវធ្វើចប់សព្វគ្រប់)។ ការនេះនឹងមានរួមទាំងការបញ្ចេញព័ត៌មានទៅឲ្យក្រុមហ៊ុនអាកាសចរណ៍ និងភ្នាក់ងារខាងការធ្វើដំណើរចំពោះការចាត់ចែងអ្នកដំណើរ តាមរយៈប្រព័ន្ធធ្វើរបាយការណ៍ជឿនលឿនតាមបណ្តាញ និងការចាត់ចែងទិដ្ឋាការតាមបែបអេឡិចត្រូនិច។

ក្រសួងក៏ផ្តោះប្តូរព័ត៌មានផងដែរជាមួយបណ្តាប្រទេស ឬអង្គការអន្តរជាតិនានាដែលមានការព្រមព្រៀងចែករំលែកព័ត៌មានជាមួយប្រទេសអូស្ត្រាលី មានរួមទាំង ក៏ប៉ុន្តែពុំមែនកំណត់ត្រឹមនេះឡើយ: សហរដ្ឋអាមេរិក អង់គ្លេស កាណាដា និងញូវហ្សេឡង់។ ការផ្តោះប្តូរព័ត៌មានទាំងនេះអាចទាក់ទិននឹងការចែកចាយនូវជីវមាត្រ (ព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គល)។

ប្រសិនបើមានការផ្គុំស៊ីគ្នា ជាមួយព័ត៌មានដែលអាចសំគាល់ដឹងអំពីបុគ្គលរបស់លោកអ្នក ក្រសួងអាចបញ្ចេញទិន្នន័យនៃជីវប្រវត្តិរបស់លោកអ្នក ច្បាប់ចម្លង ឯកសារធ្វើដំណើរ និងអត្តសញ្ញាណដទៃទៀត ឬព័ត៌មានចេញពីឯកសារដូចនេះ ស្ថានភាពអន្តោប្រវេសន៍ និងប្រវត្តិអន្តោប្រវេសន៍របស់លោកអ្នក (ដែលអាចមានរួមទាំងការក្លែងបន្លំ និងបទល្មើសផ្នែកអន្តោប្រវេសន៍ណាមួយ) និងព័ត៌មានអំពីប្រវត្តិបទឧក្រិដ្ឋពាក់ព័ន្ធណាមួយ។

គោលបំណងនៃការបញ្ចេញព័ត៌មានដូចនេះ គឺដើម្បីជួយបញ្ជាក់អត្តសញ្ញាណរបស់លោកអ្នក និងដើម្បីកំណត់ថាតើលោកអ្នកបានបង្ហាញដល់ភ្នាក់ងារដទៃទៀតក្រោមអត្តសញ្ញាណដូចគ្នា ហើយមានការទាមទារដូចគ្នាឬអត់។

ប្រសិនបើលោកអ្នកកំពុងស្នើសុំទិដ្ឋាការមនុស្សធម៌ ឬទិដ្ឋាការដែលមានកិច្ចការពារនៅក្រៅប្រទេស ដែលផ្អែកលើការទាមទារប្រឆាំងនឹងរដ្ឋាភិបាលនៃប្រទេសដោយឡែកមួយ ក្រសួងនឹងពុំបញ្ចេញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកទៅឲ្យរដ្ឋាភិបាលនោះឡើយ លើកលែងតែលោកអ្នកនៅក្នុងប្រទេសអូស្ត្រាលី ហើយលោកអ្នក:

- បានស្នើសុំ ឬយល់ព្រមដើម្បីត្រឡប់ទៅប្រទេសនេះវិញ ឬ
- ត្រូវបានគេរកឃើញថា ពុំមែនជាជនដែលប្រទេសអូស្ត្រាលីមានកាតព្វកិច្ចផ្តល់កិច្ចការពារ។

| | |
|---|---|
| *គេហទំព័រ* | **www.homeaffairs.gov.au** |
| *ខ្សែទូរស័ព្ទ សាកសួរព័ត៌មានទូទៅ* | សូមទូរស័ព្ទលេខ **131 881** ក្នុងអំឡុងម៉ោងធ្វើការក្នុងប្រទេសអូស្ត្រាលី ដើម្បីនិយាយទៅកាន់អ្នកប្រតិបត្តិទូរស័ព្ទ (ព័ត៌មានថតទុកមានផ្តល់ជូន នៅក្រៅម៉ោងធ្វើការទាំងនេះ)។ ប្រសិនបើលោកអ្នកនៅក្រៅប្រទេសអូស្ត្រាលី សូមទាក់ទងជាមួយបេសកកម្មអូស្ត្រាលីដែលនៅជិតលោកអ្នកជាងគេ។ |

© COMMONWEALTH OF AUSTRALIA, 2020